**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**National Religious King**

# កិច្ចព្រមព្រៀងរវាង

**កម្មករនិយោជិតនៃរោងចក្រ តៃកា ( ខេមបូឌា ) ខបភើរេសិន** តំណាងដោយ ប្រតិភូបុគ្គលិក **និង ក្រុមហ៊ុន តៃកា ( ខេមបូឌា ) ខបភើរេសិប** ដែលមានបណ្ណពន្ធប៉ាតង់លេខ L001-10018886 ដែលមានអាស័យដ្ឋានតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ផ្លូវជាតិលេខ 4 សង្កាត់ភ្លើងឆេះរទេះ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ តំណាងដោយ លោក **NOBUO KOBAYASHI** កាន់លិខិតឆ្លងដែនលេខៈ TS393119 ស្តីពីការព្យួរកិច្ចសន្យាការងារចំពោះកម្មករនិយោជិតមួយចំនួន ដោយបែងចែកជា ៤ ដំណាក់កាល ដោយក្រុមហ៊ុន រងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ នៃវិបត្តជំងឺកូវិដ-19 ។

## ភាគីទាំងពីរបានព្រមព្រៀងគ្នាដូចខាងក្រោម

**ប្រការ១** កម្មករនិយោជិត យល់ព្រមអោយរោងចក្រ ធ្វើការព្យួកិច្ចសន្យាការងារចំពោះកម្មករនិយោជិតមួយចំនួន ៥៥ នាក់ ចាប់ពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២០។

**ប្រការ២** កម្មករនិយោជិត យល់ព្រមអោយក្រុមហ៊ុនផ្តល់ឧបត្ថម្ភសំរាប់កម្មករនិយោជិតម្នាក់ៗ ក្នុងអំឡុងពេលព្យួរកិច្ចការងារ ដោយយោងទៅតាមសេចក្តីណែនាំលេខ ០៤៥/២០ ក.ប/ស.ណ.ន.ខ.ស ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ ២០២០ ស្តីពីការព្យួរកិច្ចសន្យាការងារ និងការផ្អាកបង់ភាគទាន ប.ស.ស សម្រាប់រោងចក្រ សហគ្រាស គ្រឹះស្ថានក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារជំងឺកូវិដ-១៩ ។

**ប្រការ៣** កម្មករនិយោជិត យល់ព្រមអោយក្រុមហ៊ុន ធ្វើការស្នើសុំមកបំពេញការងាជាធម្មតាមកវិញ ក្នុងករណីក្រុមហ៊ុនទទួលបានការបញ្ជាទិញមកវិញ ព្រមទាំងទូទាត់ប្រាក់ជាក់ស្តែងតាមចំនួនថ្ងៃធ្វើការដែលបានត្រលប់មកបំពេញកិច្ចការងារវិញ។

កិច្ចព្រមព្រៀងនេះមានប្រសិទ្ធិភាពចាប់ពីថ្ងៃដែលភាគីទាំងពីរបានផ្តិតមេដៃស្នាំទុកជាភស្តុតាងលើកិច្ចសន្យានេះតទៅ ។

ថ្ងៃ ច័ន្ទ ៥រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០២០

ស្នាមមេដៃស្នាំតំណាងប្រតិភូបុគ្គលិក

ប្រាក់ ម៉ូលីពង្ស

ធឹង សុណា

តំណាងក្រុមហ៊ុន

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន តៃកា (ខេមបូឌា) ខបភើរេសិន TAICA (CAMBODIA) CORPORATION KINGDOM OF CAMBODIA

NOBUO KOBAYASHI